01009021

លេខ៖ D82/3/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Aug-2014, 13:17
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់** **ប្តូរទៅជាសាធារណៈ**

# ដីកាសម្រេចលើចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការជូនដំណឹងទាក់ទង នឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងកិច្ចស៊ើបសួរ និង សុំឯកសារពេញលេញនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**ផ្ញើជូន**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងជនសង្ស័យ**
Michael KARNAVAS
អាង ឧត្តម

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
គឹម ម៉េងឃី
គង់ ផល្លះ
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**វិធាន ៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី ៧ និងថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣។

**បានឃើញ** មាត្រា ៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង។

**បានឃើញ** *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងកិច្ចស៊ើបសួរ និងសុំឯកសារពេញលេញនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* ("ចម្លើយតប")[2]។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[2]សំណុំរឿង ០០៣ ឯកសារ D82/3/4 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការជូនដំណឹងទាក់ទង នឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងកិច្ចស៊ើបសួរ និងសុំឯកសារពេញលេញនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤។

**បានឃើញ**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំធ្វើចំណាត់ថ្នាក់ឯកសារចម្លើយតប ជាឯកសារ "សម្ងាត់សម្ងាត់" និងការត្រៀមរួចរាល់របស់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីដាក់សំណៅកោសលុប នៃចម្លើយតប ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថាសមស្រប។

**បានឃើញ**ថា ចម្លើយតប សំដៅលើភស្តុតាងសម្ងាត់នៅក្នុងសំណុំរឿង រាប់បញ្ចូលទាំងឈ្មោះសាក្សីនានា និងលក្ខណៈនៃភស្តុតាងរបស់សាក្សី។

**បានពិចារណា**ថា ការស៊ើបអង្កេតសំណុំរឿង ០០៣ នៅតែកំពុងបន្តដំណើរការ។

**បានពិចារណាទៀត**ថា តាមវិធានផ្ទៃក្នុង មាស មុត មិនមានសិទ្ធិឆ្លើយតបទៅនឹងចម្លើយតប ដូច្នេះ មាស មុត នឹងមិនទទួលរងផលប៉ះពាល់ណាមួយពីការកោសលុបភស្តុតាងដែលបានលើកយោងនេះឡើយ នៅក្នុងដំណាក់កាលនេះ។

**អាស្រ័យហេតុនេះ ខ្ញុំ MARK B. HARMON ៖**

**បង្គាប់** សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការចាប់តាំងពីពេលចេញការជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវដាក់សំណៅកោសលុបនៃចម្លើយតប ដោយលុបចោលការលើកយោងទាំងអស់ដែលអាចនាំឲ្យបង្ហាញអត្តសញ្ញាណរបស់សាក្សីនានានៅក្នុងសំណុំរឿង ០០៣ ។

ដើម្បីពន្លឿនការដាក់សំណៅកោសលុបនៃចម្លើយតប ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**